# កុំស្រឡាញ់ស្រីក្នុងវ័យសិក្សា

(បទពាក្យ៧)

បុរាណបានចែងសុភាសិត ឱ្យកូនចៅគិតពិចារណា
កុំស្រឡាញ់ស្រីវ័យសិក្សា ព្រោះនាំបរាជ័យដល់ខ្លួន ។
យុវវ័យប្រុសស្រីគិតឱ្យច្បាស់ កុំប្រឹងជំនះគេចបំពួន
ពាក្យពេចន៍ចែងចារតាមចុងចួន ជួយជាសំនួនបានរិះគិត ។
ក្នុងវ័យសិក្សាជាវ័យស្រួត ពង្រឹងចង្កូតនៃជីវិត
តំកល់ចិន្តាឱ្យសក្តិសិទ្ធិ តាំងក្នុងកំរិតឥតឃ្លេងឃ្លោង ។
ហត្ថាកាន់ប៊ិចរលឹកនៅ ភ្នែកមើលសៀវភៅកុំរំលង
ចិត្តគិតមេរៀនគ្រប់ពេលម៉ោង ពិនិត្យចាប់ឈោងយកបញ្ញា ។
អារម្មណ៍ខំផ្តោតចោទរឿងរៀន ចំណេះរបៀនកាត់សង្កា
កុំគិតរំលែកប៉ែកស្នេហា ព្រោះជាកត្តាឱ្យរាយមាយ ។
ឥទ្ធិពលស្នេហាខ្លាំងក្លាណាស់ បើជ្រុលប្រទះដោះមិនងាយ
ទោះរឹងជាងដែកក៏អាចជ្រាយ នេះជាទំនាយច្បាប់លោកិយ។
វាទាញប្រយឺតរឹតប្រតោង រាល់គ្រប់ពេលម៉ោងស្អិតពេកក្រៃ
រុំស្រោបដួងចិត្តភ្លេចអ្វីៗ នឹកឃើញតែស្រី-ប្រុសសង្សារ ។
បើកសៀវភៅអានចិត្តងាករេ គិតដល់គូស្នេហ៍ស្រស់សង្ហា
ភ្នែកមើលមេរៀនឃើញភក្ត្រា ផូរផង់ដូចផ្កាថ្ងាប៉ប្រិម ។
មាត់ប្រឹងទន្ទេញក្បួនតម្រា អារម្មណ៍នោះណាំហោះត្រដឹម
ទៅជួបគូស្នេហ៍ឈរញញឹម រលករលឹមតាមវាយោ ។
ទោះដើរឬដេកត្រេកកួចគិត ស្នេហាចាំងបិទចិត្តជាប់មោហ៍
ភ្លេចភ្លាំងមេរៀនច្រើនកៀរគរ ដោយសារជំនោរជំនន់ស្នេហ៍ ។
រវើរវាយចិត្តឥតមូល រៀនក៏មិនចូលអារម្មណ៍ប្រែ
ណាត់ដើរណាត់ជួបជាហូរហែ ប្រើល្បិចគេចកែវេះសាលា ។
ពេលគ្រូពន្យល់ស្តាប់មិនបាន ចេះតែរំខានក្នុងចិន្តា
ធុញថប់ស្អប់ណាយការសិក្សា គ្រប់វិញ្ញាសាធ្លាក់រាយប៉ាយ ។

ទៅមុខមិនរួចថយមិនបាន　　ខ្មាស់មិត្តគ្រប់ប្រាណគេហួសឆ្ងាយ
អស់ក្តីសង្ឃឹមផ្ដឹមចិត្តណាយ　　លែងនឹកលែងស្តាយការសិក្សា ។
អនាគតត្រូវភ្លឺពណ្ណរាយ　　ត្រឡប់ប្រែក្លាយជាអន្ធការ
ភពអវិជ្ជាជាប់កាយា　　រនាំងទុក្ខាសើចចំអក ។
វិប្បដិសារីស្តីដៀលជេរ　　កំលៅជាមេស៊ីគ្រប់ច្រក
បំផ្លាញទាំងខ្លឹមទាំងសំបក　　ចិន្តាខូចខកខ្មាស់អ្នកផង ។
ជូនខ្មាស់ខ្លះស្តាយរឿងអតីត៍　　គំនិតគិតខ្លីទារសំណង
សំលាប់ខ្លួនឯងគេចសៅហ្មង　　គេចរឿងកន្លងបែបផុយៗ។
នេះគឺលទ្ធផលនៃស្នេហា　　ក្នុងវ័យសិក្សាចារតម្រុយ
កុំសាក កុំល កុំប្រថុយ　　ក្រែងរលួយស្អុយអាប់រាសី។
ថ្វីបើមនុស្សលោកមានតណ្ហា　　ឆ្លងជ្រោះកាមាទាំងប្រុសស្រី
មិនអាចចៀសផុតធ្លាក់លោកិយ　　ចាស់ក្តីក្មេងក្តីគ្រប់អង្គា។
ប៉ុន្តែបុរាណបានពោលទុក　　បែងចែកទំនុកពេលវេលា
គឺវ័យសិក្សាលោកអោយរៀរ　　មិនត្រូវប៉ះពាររឿងស្នេហា។
ព្រោះនាំឱ្យបែកខូចអារម្មណ៍　　ចិត្តមិនមូលផ្តុំក្នុងកិច្ចការ
រាយមាយបែកសាយធ្លាយចិន្តា　　ជីវិតសិក្សាពុំល្វូតលាស់ ។
បើរៀនចប់ហើយមិនថាអ្វី　　រកប្អូនដប់ម្ភៃមិនជំទាស់
មិនហាមប្រាមឃាត់មាត់រមាស់　　កុំតែរលាស់ចោលសីលធម៌ ។
សុភាសិតនេះប្រាជ្ញបំផុស　　មិនប្រាប់តែប្រុសឱ្យបវរ
ប្រដៅគ្រប់ភេទឱ្យបានល្អ　　ប្រុសស្រីខ្មៅសកុំកន្តើយ ។
គេចរឿងស្នេហ៍ស្និទ្ធចាប់ប៉ាកា　　សៀវភៅសិក្សាស្រវាត្រើយ
ស្វះស្វែងវិជ្ជាមកកៀកកើយ　　ជីវិតបានល្វើយខ្ពស់ថ្លៃថ្លា ។
វិជ្ជាមានហើយស្បើយទុក្ខចុះ　　ធម្មជាតិចំរុះពេញសួនច្បារ
កុលាបច័ន្ទម្លិះត្រៀបត្រា　　ភូមិរិន្ទភមរារើសតាមចិត្ត ។

យកម្តេចយកចុះតាមចិន្តា ឱ្យតែស្នេហាភក្តីពិត
គង់សុខសួស្តីក្នុងជីវិត រស់រួមស្នេហ៍ស្និទ្ធឥតកម្មពៀរ ។
កាព្យតែងថ្លៃងន័យវ័យសិក្សា ទឹកខ្មៅវាចាថាសូមលា
បើខុសកុំប៉ងចងវេរា សូមញាតិគ្រប់គ្នាបានសុខសាន្ត ។

*(០៨ វិច្ឆិកា ១៩៩៩)*

*ភិក្ខុ ស្វាត សាលឿម*